# របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម

## I. សេចក្តីផ្តើម

### 1. ស្ថានភាពភូមិសាស្ត្រ ខេត្តកំពង់ចាម

ខេត្តកំពង់ចាម ស្ថិតនៅដែនដីភាគខាងកើតប្រទេសកម្ពុជា ដែលមានចម្ងាយ ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ខេត្តក៏មានផ្លូវជាតិសំខាន់ៗឆ្លងកាត់ដូចជា ផ្លូវជាតិលេខ 6A ផ្លូវជាតិលេខ 7 ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ និងខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែង ខេត្តកណ្តាល ខាងកើតជាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ខាងលិចជាប់ខេត្តកំពង់ឆ្នាំង ។

បច្ចុប្បន្នខេត្តកំពង់ចាមចែកចេញជា ស្រុក-ក្រុង ឃុំ-សង្កាត់ និងភូមិរដ្ឋបាល ដែលមានក្រុងចំនួន ០១ក្រុង មានសង្កាត់ ០៤សង្កាត់ និងស្រុកចំនួន ០៩ស្រុក មានឃុំចំនួន ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ ។

ខេត្តកំពង់ចាមមានផ្ទៃដីសរុប ៤៥៤៤,០៩គ.ម២ ហើយមានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀង កសិឧស្សាហកម្មផងដែរ ។ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ១.០៩៧.០៨៥នាក់ ចំនួនស្ត្រីសរុប ៥៦២.០៨៥នាក់ ចំនួនគ្រួសារសរុប ២៥១.៤៥៨គ្រួសារ ដង់ស៊ីតេ ២៤១នាក់/គ.ម២ ប្រជាកសិករប្រកបមុខរបរកសិកម្មចំនួន ៨០% មុខរបរសិប្បកម្ម ០.៨% សេវាកម្ម ១៦% មុខរបរមិនច្បាស់លាស់(ចម្រុះ) ៣.២០% ។

### 2. ស្ថានភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ ១៩៩៤ រហូតដល់សព្វថ្ងៃមានការិយាល័យ ២០ ហើយចែកចេញជា ១០ការិយាល័យថ្នាក់ខេត្ត និង ១០ការិយាល័យ ថ្នាក់ស្រុក-ក្រុង ដោយមានមន្ត្រីសរុបចំនួន ៧២នាក់ ក្នុងនោះមានស្រីចំនួន ២១នាក់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ដឹកនាំដោយប្រធានមន្ទីរ ១រូប អនុប្រធានមន្ទីរ ០៧រូប និងប្រធាន-អនុប្រធានការិយាល័យមន្ទីរ និងថ្នាក់ស្រុកចំនួន ៦៤នាក់ ។

## II. សកម្មភាពតាមការិយាល័យនីមួយៗថ្នាក់ខេត្ត

### 1. ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន ៧២នាក់/ស្ត្រី ២១នាក់

- ថ្នាក់ដឹកនាំមន្ទីរ ប្រធានមន្ទីរ ០១រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធានមន្ទីរចំនួន ០៧រូប ក្នុងនោះមានស្ត្រី ០១ រូប ។
- ការិយាល័យថ្នាក់មន្ទីរទាំង ១០ មានបុគ្គលិកសរុប ៣៧នាក់/ស្ត្រីមាន ១១នាក់ ក្នុងនោះមានប្រធានការិយាល័យ ០៧នាក់/ស្រី ០២នាក់ ។
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ២៧នាក់/ស្ត្រីចំនួន ០៩នាក់ ក្នុងនោះមានប្រធានការិយាល័យ ០២នាក់ ស្រីគ្មាន និងអនុប្រធានការិយាល័យ ០៨នាក់/ស្រី ០១នាក់ ។
- ធ្វើលិខិតចេញបានចំនួន ២០៨ច្បាប់ និងទទួលលិខិតចូលចំនួន ១២៥ច្បាប់ ។
- បានរៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ ចំពោះមន្ត្រីការិយាល័យថ្នាក់ខេត្ត ជូនសាលាខេត្ត និងក្រសួង ។
- ធ្វើរបាយការណ៍ប្រចាំខែជូនសាលាខេត្ត និងក្រសួងទៀងទាត់រៀងរាល់ប្រចាំខែ ។

### 2. ការងារគណនេយ្យ និង ហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណទាន | បណ្តាខែមុន | ចំណាយក្នុងត្រីមាស | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 180,500,000 | | 6,144,880 | 6,144,880 | 174,355,120 |
| ៦១ | សេវាខាងក្រៅ | 909,000,000 | | | | 909,000,000 |
| ៦៤ | បន្ទុកបុគ្គលិក | 827,000,000 | | 168,905,640 | 168,905,640 | 658,094,360 |
| ៦៣ | | 1,000,000 | | | | 1,000,000 |
| | សរុប | 1,917,500,000 | - | 175,050,520 | 175,050,520 | 1,741,449,480 |

3. ការងារផែនការ និងស្ថិតិ

- **អធិការកិច្ច**
  - ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៦ ក្រុមប្រតិភូអធិការកិច្ចដឹកនាំដោយ **ឯកឧត្តម ម៉ិន ចំន្ទវណ្ណា**: អគ្គាធិកា បានធ្វើការត្រួតពិនិត្យលើរបៀបរបបធ្វើការ ការអនុវត្តចំណូលចំណាយថវិការជូរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- **កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:**
  - ប្រធាន-អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួន បានចូលរួមប្រជុំផ្សេងៗចំនួន ៦០លើក ។

III. **សកម្មភាពតាមវិស័យ**

1) ការិយាល័យផ្លូវជនបទ

១- ការងារជួសជុលបន្ទាន់ របស់នាយកដ្ឋានផ្លូវលំជនបទ

២- ការងារសាងសង់ក្រាលគ្រួសក្រហម និងផ្លូវបេតុងរបស់គម្រោង ADB ទឹកជំនន់

- សាងសង់ផ្លូវក្បាលកោះ អូរឡេង ប្រភេទផ្លូវក្រាលក្រួសក្រហម ឃុំកោះអណ្តែត ស្រុកស្រីសន្ធរប្រវែង ១០,៤៨០ ម៉ែត្រ សម្រេចបាន ៩០% ។
- ផ្លូវក្បាលកោះ អូរឡេង ប្រភេទបេតុង ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ប្រវែង ១,១២០ម៉ែត្រ សម្រេចបាន ១០០% ។

៣- ការងារសាងសង់ផ្លូវបេតុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

- ផ្លូវសាលាបឋមសិក្សាពាមជីកងទៅដំណាក់ស្មាយ សម្រេចបាន ៩០% ។

៤- ការងារថែទាំផ្លូវជាលក្ខណ:ខួបរបស់មន្ទីរអភិវឌ្ឍន៍ជនបទ

- ផ្លូវក្នុងពាមជីកង ស្រុកកងមាស មានប្រវែង ១០,០៩៩ម៉ែត្រ សម្រេចបាន ២០%
- ផ្លូវពាមប្រធ្នោះ ព្រែកតាកែ ស្រុកកោះសូទិន ប្រវែង ៥,៨០០ម៉ែត្រ
- ផ្លូវហាន់ជ័យ-ស្រក ស្រុកកំពង់សៀម មានប្រវែង ៨,០០០ម៉ែត្រ
- ផ្លូវក្នុងឃុំកៀនជ្រៃ ស្រុកកំពង់សៀម ប្រវែង ៦,២០០ម៉ែត្រ

៥- ការងារថែទាំផ្លូវជាលក្ខណ:ខួបរបស់គម្រោង RIP (III)

- ផ្លូវត្រពាំងបេង-អណ្តូងផ្តៅ ឃុំបារ៉ាយ និង ឃុំថ្មពូន ស្រុកព្រៃឈរ ប្រវែង ៧,១០០ម៉ែត្រ
- ផ្លូវរលួស ចចក ឃុំបុស្សខ្នុរ និងឃុំត្រពាំងព្រះ ស្រុកចំការលើ និងព្រៃឈរ ប្រវែង ៥,៣០០ម៉ែត្រ
- ផ្លូវជាតិលេខ៧ មៀន-កំពង់សំណាញ់ ឃុំមៀន ស្រុកព្រៃឈរ ប្រវែង ៦,០០០ម៉ែត្រ

- ផ្លូវក្រឡា-វត្តអង្គរ ឃុំក្រឡា និងអំបិល ស្រុកកំពង់សៀម ប្រវែង ៨,១២០ម៉ែត្រ

**៦- ការងារស្រង់ទិន្នន័យខ្សែផ្លូវ និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ**

- ការងារស្រង់ទិន្នន័យខ្សែផ្លូវក្នុងផែនការ ២១ខ្សែ ប្រវែង ២១គីឡូម៉ែត្រ
- ការងារធ្វើបច្ចុប្បន្នភាពខ្សែផ្លូវក្នុងផែនការ ១០៣ខ្សែ ប្រវែង ៤៦៨គីឡូម៉ែត្រ

**៧- ការងារចុះសិក្សាផ្លូវ**

- បានចុះសិក្សាផ្លូវចាប់ពីផ្សារបែកអន្លង់ទៅវត្តទួលសំបួរ មានប្រវែង ១៧,១០០ម៉ែត្រ ស្ថិតនៅក្នុងឃុំអារក្សត្នោត និងឃុំទួលសំបួរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។
- បានចុះសិក្សាផ្លូវពីភូមិថ្មគោលទៅភូមិហាន់ជ័យ មានប្រវែង ១៧,៤០០ម៉ែត្រ ដែលស្ថិតនៅក្នុងឃុំរអាង គៀនជ្រៃ វិចេក និងឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

2) <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

ការិយាល័យផ្គត់ផ្គង់ទឹកជនបទ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ មានសកម្មភាពដូចខាងក្រោម ÷

**១- ការងារចុះបណ្តុះបណ្តាល ស្តីពី ការធ្វើតេសគុណភាពទឹករកសារធាតុពុលអាសេនិច**

សមាសភាពចូលរួមដូចខាងក្រោម÷

| | |
|---|---|
| - ជនបង្គោល ក្រុមប្រឹក្សាឃុំ ចំនួន ៥ឃុំ (១ឃុំ ២នាក់) | ១០នាក់ |
| - មេភូមិ និងអនុភូមិ ៥ឃុំ = ៤៥ភូមិ (១ភូមិ ២នាក់) | ៩០នាក់ / ស្រី ១១នាក់ |
| - ឃុំស្វាគង សរុប | ២៧នាក់ / ស្រី ៦នាក់ |
| - ឃុំព្រៃកកុយ សរុប | ១៩នាក់ / ស្រី ២នាក់ |
| - ឃុំរកាអារ សរុប | ២៣នាក់ / ស្រី ២នាក់ |
| - ឃុំរាយប៉ាយ សរុប | ២១នាក់ |
| - ឃុំខ្នោ សរុប | ២៥នាក់ / ស្រី ៦នាក់ |

**២- ការងារសហការ**

មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកជនបទបានសហការជាមួយអង្គការទឹកស្អាត ១០០១ ចុះជ្រើសរើសស្ថានីយ៍ផលិតទឹកសុទ្ធបានចំនួន ០៨កន្លែងដូចខាងក្រោម÷

| | | |
|---|---|---|
| - ស្រុកកោះសូទិន | ឃុំពាមប្រធ្នោះ | ចំនួន ០១កន្លែង |
| | ឃុំល្វេ | ចំនួន ០១កន្លែង |
| - ស្រុកកំពង់សៀម | ឃុំរអាង | ចំនួន ០១កន្លែង |
| | ឃុំកោះមិត្ត | ចំនួន ០១កន្លែង |
| | ឃុំស្រក | ចំនួន ០១កន្លែង |
| - ស្រុកកងមាស | ឃុំពាមជីកង | ចំនួន ០១កន្លែង |
| | ឃុំស្តៅ | ចំនួន ០១កន្លែង |
| - ស្រុកព្រៃឈរ | ឃុំត្រពាំងព្រះ | ចំនួន ០១កន្លែង |

**៣- ការងារជីកអណ្តូងលូ**

| | | | |
|---|---|---|---|
| - ស្រុកកងមាស | ឃុំរាយប៉ាយ | ភូមិរាយប៉ាយលើ | ចំនួន ០៦អណ្តូង |

ភូមិព្រែកប្រណាក    ចំនួន ០៤កន្លែង

- ចាក់កង់លូ    បានចំនួន    ២៦៨កង់លូ

3) <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

- ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះជំរុញការងារតាមសាលារៀន នៅស្រុកស្រីសន្ធរ សាលាស្វាយសាច់ភ្នំ មានអ្នកចូលរួម ៧នាក់/ស្រ្តី ២នាក់ ។
- ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះជំរុញការងារអនាម័យនៅតាមសាលារៀនបឋមសិក្សាក្បេរ ឃុំព្រែករំដេង មានអ្នកចូលរួម ០៦នាក់/ស្រ្តី ០២នាក់ ។
- ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះជំរុញការងារអនាម័យនៅតាមសាលារៀនបឋមសិក្សា ព្រែកឳជ្រឹង ឃុំព្រែករំដេង មានអ្នកចូលរួម ០៥នាក់/ស្រ្តី ០១នាក់ ។
- ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៦ មន្ត្រីចូលរួមប្រគល់សម្ភារៈរូបវន្ត នៅសាលាបឋមសិក្សាក្បេរ ឃុំព្រែករំដេង ស្រុកស្រីសន្ធរ អ្នកចូលរួមមាន ១៥នាក់/ស្រ្តី ៤នាក់ ។
- ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៦ មន្ត្រីចូលរួមប្រគល់សម្ភារៈរូបវន្ត នៅសាលាបឋមសិក្សាដំណាក់ស្វាយ ឃុំល្វេ ស្រុកកោះសូទិន អ្នកចូលរួមមាន ២១នាក់/ស្រ្តី ៥នាក់ ។
- ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមប្រកាសភូមិ ODF នៅភូមិអូរកំបោរ ឃុំបារាយណ៍ ស្រុកព្រៃឈរ ។
- ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៦ ចុះត្រួតពិនិត្យតាមដានការងារសាងសង់បង្គន់នៅឃុំកោះអណ្តែត ស្រុកស្រីសន្ធរ មានអ្នកចូលរួម ៤៣នាក់/ស្រី ១៧នាក់ អ្នកស្ម័គ្រចិត្តសាងសង់បង្គន់មានចំនួន ៥នាក់ ។
- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៦ បានចូលរួមទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០១៦ ខួបលើកទី ១០៥ ក្រោមប្រធានបទ វិនិយោគសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមអធិបតីភាព ឯឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅភោជនីយដ្ឋានទន្លេបាសាក២ រាជធានីភ្នំពេញ ។
- ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៦ ចូលរួមពិធីប្រកាសតែងតាំងប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៦ មន្ត្រីការិយាល័យបានចូលរួមសិក្ខាសាលា ស្តីពីបូកសរុបលទ្ធផលបញ្ចប់គម្រោង និងយុទ្ធសាស្រ្តចាកចេញរបស់គម្រោងលើកកម្ពស់អនាម័យបឋម ក្នុងសហគមន៍ជនបទ ជុំទី១ នៅសាលាស្រុកស្ទឹងត្រង់ (NAS) ។
- ថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៦ មន្ត្រីការិយាល័យចុះត្រួតពិនិត្យតាមដាន ការសាងសង់បង្គន់ នៅឃុំរកាគយ ស្រុកកងមាស មាន ៤ភូមិ អ្នកចូលរួមសរុប ៤៤នាក់/ស្រី ៣០នាក់ ។
- ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៦ មន្ត្រីការិយាល័យចុះតាមដានត្រួតពិនិត្យ ការសាងសង់បង្គន់ ឃុំរកាគយ ស្រុកកងមាស មាន ០៣ភូមិ អ្នកចូលរួម សរុប ៣៣នាក់/ស្រី ២៥នាក់ ។
- ចូលរួមសិក្ខាសាលា ស្តីអំពីការបូកសរុបលទ្ធផលបញ្ចប់គម្រោង និងយុទ្ធសាស្រ្តចាកចេញរបស់គម្រោង លើកកម្ពស់អនាម័យបឋម ក្នុងសហគមន៍ជនបទ ជុំទី១ នៅសាលាស្រុកព្រៃឈរ (អង្គការ NAS)
- ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៦ ចូលរួមសិក្ខាសាលា ស្តីពី បូកសរុបរបាយការណ៍បញ្ចប់គម្រោងលើកកម្ពស់អនាម័យជនបទ នៅស្រុកកងមាស (អង្គការទឹកភ្លៀងកម្ពុជា) ។
- ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៦ មន្ត្រីការិយាល័យចូលរួមសិក្ខាសាលា នៅស្រុកបាធាយ (អង្គការទឹកភ្លៀងកម្ពុជា) ។

4) <u>ការងារអភិវឌ្ឍន៍សហគមន៍ជនបទ</u>

- ថ្ងៃទី ២១ ដល់ ២២ ខែមករា ឆ្នាំ២០១៦ ចូលរួមវគ្គបណ្តុះបណ្តាលវិធីសាស្ត្រអង្កេតស្តីពី ចំណេះដឹង ឥរិយាបថ និង ការប្រតិបត្តិ នៅភោជនីដ្ឋានអូរប៉េរ៉ា ភ្នំពេញ ។
- ថ្ងៃទី ០២ ដល់ ០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះតាមដាន និងពង្រឹងសម្ថភាព គ.អ.ភ បានចំនួន ០៣ភូមិ (ភូមិស្វាយព្រៃ ភូមិសូដី និងភូមិត្រពាំងឫស្សី) ក្នុងឃុំសំរោង ស្រុកព្រៃឈរ ដែលមានអ្នកចូលរួមសរុប ១៤នាក់(ស្រី ០៤នាក់) ។
- ថ្ងៃទី ១៦ ដល់ ១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះតាមដាន និងពង្រឹងសម្ថភាព គ.អ.ភ បានចំនួន ០៣ភូមិ (ភូមិព្រៃខ្វាយ ភូមិកណ្តោលកោង និងភូមិសំរោង) ក្នុងឃុំសំរោង ស្រុកព្រៃឈរ ដែលមានអ្នកចូលរួមសរុប ១៤នាក់/ស្រ្តី ០២នាក់។
- ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមសន្និបាទបូកសរុបការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៦ នៅសាលសន្និសីទចតុមុខ ។
- ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦ ចូលរួមសម្ភាតអនាម័យនៅទីលានបុណ្យទន្លេលើកទី២ ក្រុងកំពង់ចាម ។
- ចុះតាមដាន និងពង្រឹងសម្ថភាព គ.អ.ភ បានចំនួន ០៥លើក គឺឃុំសំរោង ០៣លើក ស្មើ ០៩ភូមិ អ្នកចូលរួមមាន ៤២នាក់/ស្រី ១០នាក់ ឃុំថ្មពូន ០១លើក ស្មើ ០៣ភូមិ មានអ្នកចូលរួម ១២នាក់/ស្រី ០៣នាក់ និងឃុំបឹងណាយ ០១លើក ស្មើ ០៣ភូមិ មានអ្នកចូលរួម ១៤នាក់/ស្រី ០៤នាក់ ។

5) <u>ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>

**១- គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**

- ស្រុកចំនួន ០៤ស្រុក ឃុំចំនួន ១៤ឃុំ ភូមិចំនួន ៤២ភូមិ
- អតិថិជនសរុបចំនួន ៧៩៧នាក់ ស្រីចំនួន ៦៥៤នាក់
- ក្រុមចំនួន ៤៣៦ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ១៧៣,៣០០,០០០រៀល
- ប្រាក់ដើមសងចំនួន ១៩០,៥០១,៤០០រៀល
- ប្រាក់ការសងចំនួន ២៦,៨៨២,៤០០រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ១,៣២៨,៦៦២,៤០០រៀល

**២- គម្រោងឥណទានកូវ៉េ**

- ស្រុកចំនួន ០២ស្រុក ឃុំចំនួន ០៣ឃុំ ភូមិចំនួន ០៨ភូមិ
- អតិថិជនសរុបចំនួន ៩២នាក់ ស្រីចំនួន ៦៧នាក់
- ក្រុមចំនួន ៤៩ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ២២,៥០០,០០០រៀល
- ប្រាក់ដើមសងចំនួន ២៧,៥៣០,០០០រៀល
- ប្រាក់ការសងចំនួន ៨,២៨៤,៤០០រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ១៤៥,៥៦៩,៤០០រៀល

**៣- ឥណទានអភិវឌ្ឍន៍សហគមន៍ជនបទស្រុកបាធាយ**

- ស្រុកចំនួន ០១ស្រុក ឃុំចំនួន ០១ឃុំ ភូមិចំនួន ០២ភូមិ
- អតិថិជនសរុបចំនួន ៤៥៩នាក់ ស្រីចំនួន ៤៥៩នាក់
- ក្រុមចំនួន ៩៨ក្រុម

- ប្រាក់ដើមឱ្យខ្ចីចំនួន ៤៥,១៥០,០០០រៀល
- ប្រាក់ដើមសងចំនួន ៤០,៧០០,០០០រៀល
- ប្រាក់ការសងចំនួន ២,៣៦១,០០០រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ៨៦,៥៥០,០០០រៀល

6) <u>**ការងារអភិវឌ្ឍន៍បណ្តុះបណ្តាល និងស្រាវជ្រាវ**</u>

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនជំនាញជូនដល់ប្រជាពលរដ្ឋក្រីក្រ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម បានចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន សំដៅឱ្យយុវជន យុវនារីក្រីក្រ កំព្រា ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀត ដើម្បីឱ្យពួកគេមានជំនាញមួយពិតប្រាកដ ។ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន បានធ្វើការផ្សព្វផ្សាយទៅដល់ភូមិ-ឃុំ តាមរយៈមន្ត្រីការិយាល័យស្រុក-ក្រុងទាំង ០៩ស្រុក ០១ក្រុង ខេត្តកំពង់ចាម និងបានផ្សព្វផ្សាយតាមវិទ្យុខេត្ត ដើម្បីជ្រើសរើសសិស្សចូលរៀនតាមមុខជំនាញ ។

❖ **ការងារបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌល**

ក្នុងខែមករា និងខែមីនា ឆ្នាំ២០១៦ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាម បានធ្វើការចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមតាមភូមិ ឃុំ ស្រុក ក្រុង ក្នុងខេត្ត ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន របស់មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាម ដែលមានជំនាញដូចខាងក្រោម÷

- ជំនាញកុំព្យូទ័រការិយាល័យ
- ជំនាញជួសជុលទូរស័ព្ទ
- ជំនាញជួសជុលម៉ូតូ
- ជំនាញកែសម្ផស្ស និងអ៊ុតសក់

ក្រោយពីធ្វើការចុះផ្សព្វផ្សាយនៅតាមមូលដ្ឋានកន្លងមក មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម នៅក្នុងខែមីនា ឆ្នាំ២០១៦ បានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដូចខាងក្រោម÷

- ជំនាញកុំព្យូទ័រការិយាល័យមានសិក្ខាកាមចំនួន ២២នាក់/ស្រី ១២នាក់

❖ **ការងារសហគមន៍**

➢ **មន្ត្រីរាជការដែលកំពុងសហការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ**

- គម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ១៥នាក់
- អង្គការ ADB ០៦នាក់
- អង្គការយូនីសេហ្វ (UNICEF) ០៥នាក់
- កម្មវិធី RIP ០៤នាក់

➢ **ការងារសហការជាមួយអង្គការ NGOs**

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម បានសហការណ៍ជាមួយអង្គការដៃគូមួយចំនួនដែលទទួលបានការគាំទ្រ ពីមូលនិធិអនាម័យសកល (Global Sanitation Fund) មានដូចជា អង្គការ Plan អង្គការទឹកភ្លៀង អង្គការ SNV អង្គការ NAS អង្គការ CHED អង្គការទឹកស្អាត ១០០១ អង្គការ Water SHED និងអង្គការ UNICEF អប់រំអនាម័យតាមសាលារៀន និងសហគមន៍មូលដ្ឋាន ។

➢ **ការងារអង្គការយូនីសេហ្វ**

ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ ចុះពង្រឹងសមត្ថភាពដល់អាជ្ញាធរដែនដី និងវិស័យឯកជន អំពីផលប៉ះពាល់សារធាតុពុលអាសេនិចក្នុងការធ្វើទឹកអោយស្អាត និងបរិភោគទឹកដែលមានសុវត្ថិភាពដែលមានអ្នកចូលរួមដូចខាងក្រោម ÷

- ឃុំមានជ័យអ្នកចូលរួម ចំនួន ៦៩នាក់ ស្រី ២២នាក់
- ឃុំព្រែកកុយអ្នកចូលរួម ចំនួន ៦២នាក់ ស្រី ២១នាក់
- ឃុំរកាអារអ្នកចូលរួម ចំនួន ៨៧នាក់ ស្រី ៣២នាក់
- ឃុំរាយប៉ាយអ្នកចូលរួម ចំនួន ៦៤នាក់ ស្រី ១៩នាក់
- ឃុំខ្ចៅអ្នកចូលរួម ចំនួន ៧២នាក់ ស្រី ២៧នាក់
- ឃុំស្វាគងអ្នកចូលរួម ចំនួន ៨៩នាក់ ស្រី ២៥នាក់

➢ ការងារយេនឌ័រ

- ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៦ លោកស្រី ប៉ាន ផល្លីន បានចូលរួមទិវានារីអន្តរជាតិលើកទី ១០៥ នៅសាលាខេត្តកំពង់ចាម ក្រោមអធិបតីភាព ឯកឧត្តម លន់ លឹមថៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ។
- ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៦ មន្ត្រីចំនួន ២០រូប ជាស្ត្រី បានចូលរួមទិវានារីអន្តរជាតិលើកទី ១០៥ នៅក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

## IV. ទិសដៅផែនការឆ្នាំ ២០១៦

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ អង្គការ សហគមន៍នានាឱ្យមានភាពកាន់តែប្រសើរឡើង ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋមានលក្ខណៈសមស្របពីមួយថ្ងៃទៅមួយថ្ងៃ និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

## V. បញ្ហាប្រឈម

ស្របតាមសមិទ្ធផលដែលទទួលបានពីអនុវត្តន៍ការងារក្នុងឆ្នាំកន្លងមក មន្ទីរបានកត់សម្គាល់ឃើញថា មានការប្រឈមមួយចំនួននៅពេលចុះអនុវត្តន៍ការងារដូចជា ÷

- ការពង្រឹងធនធានមនុស្សដល់មន្ត្រីមន្ទីរនូវមានកម្រិត ព្រោះការបណ្តុះបណ្តាលជំនាញបច្ចេកទេស នៅពុំទាន់បានសមស្របតាមផ្លូវការ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ក្នុងការថែទាំសមិទ្ធផលដែលបានផ្តល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ លើការថែទាំសុខភាព និងអនាម័យ អប់រំផ្សព្វផ្សាយបានទូលំទូលាយ ការផ្លាស់ប្តូរទម្លាប់របស់សហគមន៍នៅមានភាពយឺតយ៉ាវ ។

## VI. សន្និដ្ឋាន

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថា ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទ បានសម្រេចលុះត្រាតែយើងបានអនុវត្តនូវសកម្មភាពដូចខាងក្រោម÷

- ធ្វើអោយមានសកម្មភាពឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ ។

- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សំណង់ធារាសាស្ត្រ ផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជនបទ របស់មន្ទីរបានបង្ហាញឱ្យឃើញថា ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍន៍ដូចជា ស្ពាន និងផ្លូវលំជនបទខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តា ធ្វើអោយប្រជាពលរដ្ឋកាន់តែជិតរវាងជនបទ និងទីប្រជុំជន ។ ធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយយល់ដឹងពីសុខភាព និងអនាម័យតាមរយៈការអប់រំផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

សរុបសេចក្ដីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានចូលរួមអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ អាណត្តិទី៥ និងគោលនយោបាយ ស្ដីពី ការផ្ដល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានល័ក្ខខ័ណ្ឌល្អប្រសើរក្នុងជីវភាពរស់នៅ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រធានមន្ទីរ**